# របាយការណ៍ប្រចាំខែមករា ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែមករា ឆ្នាំ២០១៦ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. **<u>ស្ថានភាពមន្ត្រីរាជការ</u>**÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ២៨ នាក់ ស្ត្រី ០២ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. **<u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>÷**

- ចូលរួមវេទិកាសាធារណៈចំនួន ០២ដង
- ចូលរួមពិធីបិទការប្រកួតបាលទាត់ ថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៦ នៅពហុកីឡាដ្ឋានខេត្តក្រចេះ
- ចូលរួមប្រជុំស្តីពីការចុះសិក្សាស្រាវជ្រាវវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារលើគ្រប់វិស័យប្រចាំឆ្នាំ២០១៥ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបើក និងបិទអង្គសន្និបាតបូកសរុប វាយតម្លៃការងារអប់រំឆ្នាំ២០១៤-១៥ និងទិសដៅបន្ត២០១៥-១៦ (បើកថ្ងៃ២១ ខែមករា ឆ្នាំ២០១៦ និងបិទថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ នៅសាលមហោស្រពខេត្ត)
- ចូលរួមប្រជុំគណៈកម្មការនាយកមូលនិធិសមធម៌ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ ថ្ងៃទី២៦ មករា ឆ្នាំ២០១៦ មន្ទីរពេទ្យបង្អែកស្រុកឆ្លូង
- ចូលរួមប្រជុំគណៈកម្មការនាយកមូលនិធិសមធម៌ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ ថ្ងៃទី២៦ មករា ឆ្នាំ២០១៦ មន្ទីរសុខាភិបាលខេត្ត
- ចូលរួមកម្មវិធីទិវាស្រែបង្ហាញ របស់គម្រោងកសាងភាពធន់ទៅនឹងការបម្រែបម្រួលអាកាសធាតុ និងសន្តិសុខស្បៀងក្នុងសហគមន៍ ថ្ងៃទី២២ មករា ឆ្នាំ២០១៦ នៅភូមិឈើទាលភ្លោះ ឃុំកញ្ជរ ស្រុកឆ្លូង
- ចូលរួមប្រជុំក្រុមប្រឹក្សាខេត្តលើកទី២០ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ នៅសាលក្រុមប្រឹក្សា
- ចូលរួមសិក្ខាសាលាស្តីពីប្រព័ន្ធផលិតកម្មផលិតស្រា ស ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ និងសួនកុមារ
- ចូលរួមកម្មវិធីប្រកាសតំបន់វិនិច្ឆ័យនៃការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធជូនពលរដ្ឋ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ និងវត្តចង្ក្រង់ ។

3. **សកម្មភាពតាមការិយាល័យ÷**

3.1. **ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ**

ក. ផ្នែកការងារលិខិតចូល÷ សរុបចំនួន ៣១លេខ ក្នុងនោះមាន÷

- លិខិតចូលពីអង្គភាពនានាក្រោមន្ទីរ ចំនួន ២៩ លេខ

- លិខិតក្រសួងសាមី និងអង្គភាពក្រោមឱវាទមន្ទីរ ចំនួន ០២ លេខ

ខ. ផ្នែកការងារលិខិតចេញ÷

- លិខិតចេញទៅបណ្ដាអង្គភាពនានាក្រោមន្ទី ចំនួន ០៦ លេខ
- លិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការ ចំនួន ១១ លេខ
- លិខិតចេញទូទៅ (លិខិតអញ្ជើញ និងជូនដំណឹង) ចំនួន ០៣ លេខ
- លិខិតចេញទៅបណ្ដាអង្គភាពនានា ក្រោមឱវាទ ចំនួន ០៣ លេខ

គ-ផ្នែកបញ្ជីវត្តមាន÷ ពិនិត្យការចុះបញ្ជីវត្តមានប្រចាំថ្ងៃ ។

3.2. **ការិយាល័យផ្លូវជនបទ÷**

- ក្រុមការងារនាយកដ្ឋានផ្លូវលំជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ ចុះសិក្សាផ្លូវ ចំនួន ០១ ខ្សែ ពីភូមិខ្សាច់វែង ទៅភូមិជាវជ្រៃ ប្រវែង ១៦,០០០ ម៉ែត្រ ដែលស្ថិតនៅឃុំកញ្ជរ ស្រុកឆ្លូង និងឃុំស្វាយជ្រះ ស្រុកស្នួល
- ក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទចុះសិក្សាផ្លូវ ០១ ខ្សែ ពីភូមិអូរឬស្សី២ ទៅភូមិបន្ទាយ ប្រវែង ៦,១០០ ម៉ែត្រ ដែលស្ថិតនៅសង្កាត់អូរឬស្សី ក្រុងក្រចេះ និងឃុំគោលាប់ ស្រុកចិត្របុរី
- ចុះស្រង់ទិន្នន័យផ្លូវជនបទតាមប្រព័ន្ធ GPS សម្រាប់រៀបចំផែនទីក្នុងខេត្ត បានចំនួន ០២ ខ្សែ ២១,៩០០ម៉ែត្រ ស្ថិតនៅឃុំកញ្ជរ ស្រុកឆ្លូង ឃុំបុសលាវ ស្រុកចិត្របុរី ឃុំស្វាយជ្រះ ស្រុកស្នួល
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវតាមប្រព័ន្ធ PGS បាន ០៤ ខ្សែ ប្រវែង ៤២,៦០០ ម៉ែត្រ ដែលស្ថិតនៅឃុំព្រែកប្រសព្វ ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ។

3.3. **ការិយាល័យផ្គត់ផ្គង់ទឹកជនបទ÷** (គ្មានសកម្មភាព)

3.4. **ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ÷** (គ្មានសកម្មភាព)

3.5. **ការិយាល័យអភិវឌ្ឍន៍សហគមន៍÷** (គ្មានសកម្មភាព)

3.6. **ការិយាល័យជនជាតិដើមភាគតិច÷** (គ្មានសកម្មភាព)

3.7. **ការិយាល័យថែទាំសុខភាពជនបទ÷** (គ្មានសកម្មភាព)

3.8. **ការងារបណ្ដុះបណ្ដាលមន្ត្រីរាជការ÷** (គ្មានសកម្មភាព)

4. **ទិសដៅបន្ត÷**

- ចុះស្រង់ទិន្នន័យផ្លូវតាមប្រព័ន្ធ GPS ដើម្បីរៀបចំផែនទីក្នុងខេត្ត ស្ថិតនៅស្រុកចិត្របុរី និងស្រុកស្នួល
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវតាមប្រព័ន្ធGPS ដើម្បីរៀបចំផែនទីក្នុងខេត្ត ស្ថិតនៅស្រុកចិត្របុរី និងស្រុកស្នួល ។

**ប្រធានមន្ទីរ**